**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

**<u>សេចក្តីប្រកាសព័ត៌មាន</u>**

ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ២០២១

# អូស្ត្រាលីផ្តល់សម្ភារៈបរិក្ខារពេទ្យព្យាបាលជំងឺកូវីដដល់កម្ពុជា

កាលពីថ្ងៃទី១១ ខែធ្នូ ប្រទេសអូស្ត្រាលី បានផ្តល់សម្ភារៈបរិក្ខារពេទ្យដល់កងយោធពលខេមរភូមិន្ទ ដើម្បីជួយប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។

ការប្រគល់ជំនួយដល់តំបន់យោធាភូមិភាគទី៤ (ខេត្តសៀមរាប) និងទី៥(ខេត្តបាត់ដំបង) ព្រមទាំងមូលដ្ឋានទ័ពជើងទឹករាមនេះ ជាការផ្តល់ជូនចុងក្រោយនៃជំនួយដែលបានផ្តល់ជូនជាច្រើនពីប្រទេសអូស្ត្រាលី ដែលបានកើតមានក្នុងឆ្នាំនេះ ដែលរួមមាន សម្ភារៈបរិក្ខារការពារផ្ទាល់ខ្លួន ឧបករណ៍ធ្វើតេស្តរកមេរោគកូវីដ ឧបករណ៍ពិនិត្យអ្នកជំងឺ ឧបករណ៍សម្រាប់បញ្ចូលអុកស៊ីហ្សែន និងឧបករណ៍ជំនួយដល់ការដកដង្ហើម។

ឯកឧត្តម Pablo Kang ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា បានផ្តល់អំណោយជាសម្ភារៈបរិក្ខារពេទ្យ និងឧបករណ៍ការពារផ្ទាល់ខ្លួន ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ចំនួនជាង ១ ៥០០ គីឡូក្រាម ជូនដល់ នាយឧត្តមសេនីយ៍ ម៉ឺង សំផន រដ្ឋលេខាធិការក្រសួងការពារជាតិ។ ក្នុងចំណោមនេះ បរិក្ខារប្រើប្រាស់មានដូចជា ស្រោមដៃចំនួនជាង ២០ ០០០ ម៉ាស់ចំនួន ៥០ ០០០ បង់រុំចំនួន ៣ ៨០០ និងឧបករណ៍ធ្វើតេស្តរកមេរោគកូវីដចំនួន ១០ ០០០។

ឯកឧត្តមឯកអគ្គរាជទូតបានឆ្លុះបញ្ចាំងពីចំណុចសំខាន់ៗ នៃកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិទ្វេភាគីរបស់អូស្ត្រាលី និងកម្ពុជាក្នុងកំឡុងឆ្នាំ ២០២១ រួមទាំងដំណើរទស្សនកិច្ចរបស់នាវា HMAS Anzac មកកាន់ខេត្តព្រះសីហនុ កាលពីខែតុលា ឆ្នាំ ២០២១ ដែលជា

ដំណើរទេសចរណ៍ទស្សនកិច្ចលើកទីមួយរបស់នាវាកងទ័ពជើងទឹកអូស្ត្រាលី មកកាន់កម្ពុជា ចាប់តាំងពីឆ្នាំ ២០១៦មក។

ឯកឧត្តមឯកអគ្គរាជទូតបានអបអរដល់កម្ពុជាចំពោះភាពជោគជ័យ នៃយុទ្ធនាការចាក់វ៉ាក់សាំងបានដល់ប្រជាជនរបស់ខ្លួនបានយ៉ាងឆាប់រហ័ស និងជាពិសេសកងយោធពលខេមរភូមិន្ទដែលដើរតួនាទីឈានមុខគេក្នុងការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាទាំងមូល។ "ការប្រគល់បរិក្ខារពេទ្យថ្ងៃនេះ ពង្រឹងការប្តេជ្ញាចិត្តរបស់ប្រទេសអូស្ត្រាលី ក្នុងការជួយដល់ការអភិវឌ្ឍនាពេលអនាគតរបស់កម្ពុជា រួមទាំងការស្តារឡើងវិញនូវសុខុមាលភាព និងសេដ្ឋកិច្ចពីជំងឺកូវីដ-១៩ ផងដែរ។ វាក៏គូសបញ្ជាក់នូវសេចក្តីប្រាថ្នារបស់យើងដល់កិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិយូរអង្វែង ដែលធ្វើឱ្យមានភាពចម្រុះនៅក្នុងទំនាក់ទំនងជាយុទ្ធសាស្ត្ររបស់កម្ពុជា ព្រមទាំងការពារឯករាជ្យ និងអធិបតេយ្យភាពរបស់កម្ពុជាផងដែរ"។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au